ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២២

នៅក្នុងឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន ៖

-បំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០៤លើក។

#### ១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១១លើក ប្រជុំពេញអង្គចំនួន០៥លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន ០១លើក។

#### ១.១.២-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ

-អនុញ្ញាតឱ្យថ្នាក់ដឹកនាំប្រទេសជាមិត្ត គណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ និងអង្គទូតនានា ចូលជួបជូនសារតាំង សម្តែងការគួរសម សវនាការ និងជម្រាបលា ចំនួន៣៣លើក។

#### ១.១.៣-សកម្មភាពបំពេញទស្សនកិច្ចក្រៅប្រទេស

-អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការ និងមិត្តភាព នៅសាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

#### ១.១.៤-សកម្មភាពចុះមូលដ្ឋាន

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន១៦លើក។

**១.១.៥-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានឧបត្ថម្ភថវិកាចំនួន ២០.០០០ដុល្លារ និង២០.០០០.០០០លានរៀល ជូនកាកបាទក្រហមកម្ពុជា និងរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាមីននៅកម្ពុជា

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៨០លើក។

**១.១.៥-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៣០១ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន២៩៨ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិ ចំនួន២៩៨ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន២៩១ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន០៨ច្បាប់

-បានទទួលសំណើប្រមុខរដ្ឋស្តីទីចំនួន០២ច្បាប់

-បានទទួលសំណើពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១ច្បាប់

-បានចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន៧១៦ច្បាប់ ផ្តល់យោបល់ចំនួន១២០ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៧៧ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា បាន ៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០៥លើក។

**១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន៧លើក ប្រជុំពេញអង្គចំនួន៣លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន១លើក។

**១.២.២-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន១៥លើក។

**១.២.៣-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន១៨លើក។

**១.២.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១០២ច្បាប់និងជ្រាបជាព័ត៌មាន ចំនួន៣៨៦ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន ៖**

**១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៣លើក ដឹកនាំ និងចូលរួមប្រជុំពេញអង្គចំនួន០៦លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក។

**១.៣.២-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ ចូលជួបពិភាក្សាការងារ និងសម្តែងការគួរសម ចំនួន០៤លើក។

**១.៣.៣-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន២៤លើក។

**១.៣.៤-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-បានឧបត្ថម្ភថវិកាចំនួន ២០.០០០.០០០លានរៀល ជូនដល់កាកបាទក្រហមកម្ពុជា

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៥១លើក។

**១.៣.៥-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២២១ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៧៦ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបើកសម័យប្រជុំចំនួន១៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យលើសំណើរបស់រដ្ឋសភាសុំដាក់សេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជា លេខ:០៤៤/១២២១/លគ.គក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

៣-ពិនិត្យ និងសម្រេចលើរបាយការណ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨, លើកទី៨ និងលើកទី៩ នីតិកាលទី៤។

## ៣.សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០៦លើក និងប្រជុំជាវិសាមញ្ញចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើរបៀបវារៈដូចខាងក្រោម៖

១-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨, លើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤

២-ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ ជំនួសលោកជំទាវ **ឱ សុខុម** ដែលបានទទួលមរណភាព

៣-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា នីតិកាលទី៤

៤-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់។

## ៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១-មុខងារនីតិកម្ម

-គណៈកម្មការជំនាញព្រឹទ្ធសភាបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាលចំនួន១០លើក ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន១៤ច្បាប់

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោត ស្តីពីផែនការឆ្ពោះទៅការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ

-បានអញ្ជើញប្រជុំពិនិត្យពិភាក្សាការងារជាមួយប្រធានគណៈកម្មការទី១ គណៈកម្មការទី៣ រដ្ឋសភា, រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ក្រសួងការពារជាតិ, ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លើសំណើរបស់តំណាងសហគមន៍ជនជាតិភាគតិច១៦អំបូរ ក្នុងការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ, សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងលើសេចក្តីព្រាងច្បាប់ស្តីពីរការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា

-បានអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីការបង្កើតគណៈកម្មការពិសេស និងនីតិវិធី ការងារ ដើម្បីរៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

**៤.២-មុខងារតាមដានការអនុវត្តច្បាប់**

-បានអញ្ជើញជួបសវនាការការងារជាមួយគណៈប្រតិភូក្រសួង ស្ថាប័ន នានា រួមមាន៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងព័ត៌មាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍, ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ខេត្តកោះកុង, អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ, អនុប្រធានទី១ អាជ្ញាធរអគ្គិសនីកម្ពុជា និងពុទ្ធសាសនបណ្ឌិត្យ នៅរាជធានីភ្នំពេញ, មន្ទីរកិច្ចការនារី និងមន្ទីរផែនការរាជធានីភ្នំពេញ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈមព្រមទាំងការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ

-បានអញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យ ការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ និងព័ត៌មាន ពិនិត្យតាមច្រកទ្វារព្រំដែនអន្តរជាតិ និងសម្រង់ព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ, ការពង្រឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រោយការបោះឆ្នោតសំដៅអភិវឌ្ឍន៍មូលដ្ឋាន ធានាបានសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តព្រះសីហនុ

ខេត្តកំពត ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តពោធិ៍សាត់ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង ខេត្តបន្ទាយមានជ័យ និងខេត្តមណ្ឌលគិរី

-បានអញ្ជើញចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តការងារតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ព្រមទាំងជួបសំណេះសំណាលការងារជាមួយគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ស្មៀន មេភូមិ និងនាយប៉ុស្ដិ៍នគរបាល នៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តរតនគិរី និងឧត្តរមានជ័យ

-បានអញ្ជើញចូលរួមប្រជុំអន្តរក្រសួង ស្តីពីវឌ្ឍនភាពនៃការពិនិត្យសិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ នៅក្នុងភូមិសាស្ត្រខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**៤.៣-មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន**៨៦**ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន **៨៦**ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន **៣៧**ករណី កំពុងពិនិត្យសិក្សាបានចំនួន**៣**ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន**៨១**ករណី និងបានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន**១២**ករណី និងតម្កល់ទុកមិនចាត់ការចំនួន**៥**ករណី ដោះស្រាយបញ្ចប់បាន**១**ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបបានចំនួន**៨៣**ករណី

-បានធ្វើវេទិកាស្តីពី " ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ " នៅខេត្តសៀមរាប

-បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំ សិក្ខាសាលា វេទិកា ពិធីបុណ្យជាតិ-អន្តរជាតិ និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន១.៩៤៩លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះ

សំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការសុខាភិបាល ស្តីពីវិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអំពាវនាវឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់គ្នា និងបានបំពេញភារកិច្ចផ្សេងៗទៀតនៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៣.១១៣លើក។

## ៥.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងបានទទួលលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-សមាជិកព្រឹទ្ធសភា បានអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចជាផ្លូវការ និងមិត្តភាព នៅសាធារណរដ្ឋកូរ៉េ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានាដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូ រួមមាន ៖ កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយមហាសន្និបាតសភាតំបន់អាស៊ី (APA) ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងបញ្ហាផ្សេងៗ, កិច្ចប្រជុំសភាតំបន់អាស៊ី (APA), កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃក្រុមសភាជាតិ (APF), កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង, កិច្ចប្រជុំគណៈកម្មការសភា (APF), កិច្ចប្រជុំក្រុមទទួលបន្ទុកការសើរើលក្ខន្តិកៈ (APF), កិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP), កិច្ចប្រជុំគណៈកម្មាធិការនយោបាយសម្រាប់មហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣, កិច្ចប្រជុំពិគ្រោះយោបល់នៃគណៈកម្មាធិការស្ត្រី

វ៉ាយប៉ា(WAIPA), មហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤ (IPU-144), មហាសន្និបាតលើកទី៤៧ នៃសភានិយាយភាសាបារាំង(APF), កិច្ចប្រជុំប្រចាំឆ្នាំរបស់ (AIPACODD) លើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រឿងញៀន, កិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយអាយប៉ា លើកទី១៣ ក្រោមប្រធានបទ " ការអនុវត្តលើសេចក្តីសម្រេច នៃមហាសន្និបាតអាយប៉ាលើកទី៤២ និងកិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចឌីជីថល ក្នុងអាស៊ានក្រោយវិបត្តិកូវីដ-១៩ ", កិច្ចប្រជុំរបស់វេទិកាអាស៊ីប៉ាស៊ីហ្វិក លើកទី៦ (APPFGH6) ស្តីពីសុខភាពសកល, កិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក លើកទី៣០ (APPF-30th), កិច្ចប្រជុំលើកទី១០ នៃសភាប្រើប្រាស់ភាសាបារាំង(APF), មហាសន្និបាតសហភាពអន្តរសភា លើកទី១៤៥, មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ASEAN Inter-Parliamentary Assembly) ក្រោមមូលបទ " បោះជំហានជាមួយគ្នាដើម្បីចីរភាព បរិយាបន្ន និងភាពធន់របស់អាស៊ាន ", មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកសភា ប្រើភាសាបារាំង, សិក្ខាសាលាស្តីពីពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងបានទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល ប្រទេសប៊ែលហ្ស៊ិក, ទស្សនកិច្ចនៅសមាគមសណ្តែកសៀងអាមេរិក និងទស្សនកិច្ចការងាររបស់គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយរដ្ឋសភាវៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសវនាការ ពិភាក្សាការងារ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ និងអន្តរជាតិ និងអង្គទូតនានាចំនួន២៥លើក

-សមាជិក សមាជិកាព្រឹទ្ធសភា បានទទួល និងបដិសណ្ឋារកិច្ចគណៈប្រតិភូអន្តរជាតិមកទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន០៦លើក

-បានអញ្ជើញចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយលោក KIM JUNG NAM ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ស្តីពីការផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នៅព្រឹទ្ធសភា

-បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា

ស្តីពីកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ជាមួយខុទ្ទកាល័យរដ្ឋសភាវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តម **វឿង ឌីញហ្វេ** ប្រធានរដ្ឋសភាវៀតណាម នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

ថ្ងៃអង្គារ ១២ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២៣

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

*ចម្លងជូន:*

- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*